# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
"រ.ទ.ស.ភ"

លេខ ០៦០ ស.ជ.ណ

# សេចក្តីជូនដំណឹង
## ស្តីពី
## ការបែងចែកភាគលាភរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ** (**រ.ទ.ស.ភ**) មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ភាគហ៊ុនិកកាន់កាប់ភាគហ៊ុនធម្មតា រ.ទ.ស.ភ ទាំងអស់ជ្រាបថា រ.ទ.ស.ភ នឹងបែងចែកភាគលាភជូនភាគហ៊ុនិកកាន់កាប់ភាគហ៊ុនធម្មតា ដូចខាងក្រោម៖

១- ប្រភេទភាគលាភដែលត្រូវបែងចែក(Type of Divididend): សាច់ប្រាក់
២- រយៈពេលភាគលាភ(Period of Dividend): ប្រចាំឆ្នាំ
៣- អនុបាតនៃការបែងចែកភាគលាភ(Dividend Payout Ratio): ៧%
៤- ភាគលាភសរុបដែលត្រូវបែងចែក(Total Dividend): ២.៤០៩.១៥៦.៥៨៧,៩០រៀល
៥- ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ(Dividend Per Share): ២៧,៧០រៀល
៦- កាលបរិច្ឆេទប្រកាសបញ្ជីឈ្មោះភាគហ៊ុនិកត្រូវទទួលបានភាគលាភ(RecordDate): ១០ មេសា ២០១៣
៧- កាលបរិច្ឆេទចាប់ផ្តើមទូទាត់ភាគលាភ(Payment Date): ២៤ មេសា ២០១៣

**បញ្ជាក់** ៖

១- ភាគហ៊ុនិកដែលមានសិទ្ធិទទួលបានភាគលាភដូចបានកំណត់ខាងលើ ជាភាគហ៊ុនិកដែលមានឈ្មោះនៅក្នុងបញ្ជីឈ្មោះភាគហ៊ុនិកផ្លូវការដែលទទួលបានពីបញ្ជីឈ្មោះភាគហ៊ុនិកបណ្តោះអាសន្ន ដោយបានរៀបចំឡើងនៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៣។

២- ភាគហ៊ុនិកដែលធ្វើការលក់មូលបត្រកម្មសិទ្ធិរបស់ខ្លួន នៅថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៣ នៅតែមានសិទ្ធិទទួលបានភាគលាភដដែល។

៣- ភាគហ៊ុនិកដែលធ្វើការទិញមូលបត្រកម្មសិទ្ធិ នៅថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៣ នឹងមិនមានសិទ្ធិទទួលបានភាគលាភទេ។

៤- ការទូទាត់ភាគលាភចាប់ពីថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៣ ដល់ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៣ នៅរៀងរាល់ថ្ងៃធ្វើការ។ ក្នុងករណីមានភាពមិនត្រឹមត្រូវក្នុងការទូទាត់ភាគលាភខាងលើ ភាគហ៊ុនិកអាចធ្វើការតវ៉ាចាប់ពីថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៣ ដល់ ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៣ នៅរៀងរាល់ថ្ងៃធ្វើការ។

ព័ត៌មានបន្ថែម សូមទាក់ទងទៅកាន់ **ធនាគារ អេស៊ីលីដា ភីអិលស៊ី** ជាភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់របស់ រ.ទ.ស.ភ ដូចខាងក្រោម៖

- អាសយដ្ឋាន: លេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ
- ទូរសព្ទ: (៨៥៥)២៣-៩៩៨ ៧៧៧ (ភ្ជាប់ទៅ: ៨៣១៦៧ )
- ទូរសារ: (៨៥៥)២៣-៩៩៨ ៦៦៦
- ទូរសព្ទដៃ: (៨៥៥)១៥ ៦០០ ៧៤៣ / ០៩៧ ៦៥ ៣៨ ៣៣៣
- អ៊ីម៉ែល: lim.an@acledabank.com.kh

រាជធានីភ្នំពេញ, ថ្ងៃទី០១ ខែមេសាឆ្នាំ២០១៣

**អគ្គនាយក**

**ស៊ឹម ស៊ីថា**